**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០២.២៣៦/០៧ គជប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

# កម្មវិធីផ្សព្វផ្សាយគោលនយោបាយរួមរបស់គណបក្សនយោបាយ នឹងចាប់ផ្តើមដំណើរការថត នៅដើមខែ មីនា ខាងមុខ

នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សាយ នៃ គ.ជ.ប បានរៀបចំ ពិធីចាប់ឆ្នោតយកលំដាប់លេខរៀងថត និងផ្សាយ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៥-៦-៧ ខែ មីនា ឆ្នាំ ២០០៧ នៅស្ទូឌីយោទូរទស្សន៍ជាតិកម្ពុជា ហើយនឹងត្រូវចាក់ផ្សាយចាប់ពីថ្ងៃទី ១៦-៣០ ខែ មីនា ឆ្នាំ ២០០៧ ។

ពិធីចាប់ឆ្នោតនេះធ្វើឡើងចំនួន ៥ដង លើប្រធានបទចំនួន ៥ ដែលក្នុងមួយប្រធានបទត្រូវចែកជា ៣ក្រុម ហើយក្រុមនីមួយៗមាន ៤ គណបក្សនយោបាយ ។ ការចាប់ឆ្នោតដែលមានចែកជាក្រុមនេះ ដើម្បីងាយស្រួលក្នុងការថត ព្រោះតាមលក្ខណៈបច្ចេកទេសថតម្តង ៤គណបក្សៗនេះ ធ្វើឱ្យរូបភាពឃើញចំច្បាស់ល្អ ហើយការរៀបចំឆាកក៏មានលក្ខណៈងាយស្រួលរៀបចំបានល្អផងដែរ ។

ជាមួយគ្នានេះ លោក សុកុលៈ ទីប៉ោ អគ្គលេខាធិការរង និងជាប្រធានគណៈកម្មការសម្របសម្រួលកម្មវិធីផ្សាយ នៃ គ.ជ.ប បានជម្រាបជូនដល់តំណាងគណបក្សនយោបាយទាំងអស់ អំពីបំរាមក្នុងពេលថតនោះថា ÷

១- នៅពេលដំណើរការថត អនុញ្ញាតអោយតែវាគ្មិនម្នាក់ក្នុងមួយគណបក្សចូលក្នុងស្ទូឌីយោ ។

២- មិនអនុញ្ញាតអោយអ្នកសារព័ត៌មានចូលថតរូប ឬ យកព័ត៌មានក្នុងស្ទូឌីយោឡើយ ។

៣- មិនអនុញ្ញាតអោយអ្នកសង្កេតការណ៍មានវត្តមានក្នុងពេលកំពុងដំណើរការថតឡើយ ។

៤- មិនអនុញ្ញាតអោយថតសម្លេងវាគ្មិនណាម្នាក់ក្នុងស្ទូឌីយោឡើយ ។

៥- ត្រូវបិទទូរស័ព្ទពេលកំពុងដំណើរការថត ។

សូមបញ្ជាក់ថា នៅក្នុងពិធីចាប់ឆ្នោតកំណត់យកលំដាប់លេខរៀងថត និងចាក់ផ្សាយនោះ អវត្តមានគណបក្សមួយ គឺគណបក្សសង្គមខ្មែរនិយម ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង : ទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh